**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨០ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការកាត់ដីទំហំ ១៩,២៤ ហិកតា នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចេញដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៨០/១៧ អបខ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ
- បានឃើញលិខិតលេខ៣៨៦៨ កសក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ១៩,២៤ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជា ដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដាំដុះជាក់ស្តែងទំហំ ១៧,៨១ ហិកតា និងផ្ទៃដីទំហំ ១,៤៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិជើងភ្នំ **ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ(១) និង(២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៩៨ គ្រួសារ នៅភូមិជើងភ្នំ **ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។**

**មាត្រា ៣** : ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន **១៤០ ក្បាលដី** ជូនប្រជាពលរដ្ឋ ៩៨ គ្រួសារ ស្ថិតនៅ **ភូមិជើងភ្នំ ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។**

**មាត្រា ៤** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...៥០៣ អនក្រ.បក ចុះថ្ងៃទី...២៦...ខែ...ឧសភា...ឆ្នាំ២០១៧ ស្តីពីការកាត់ឆ្វៀលផ្ទៃដីសរុបទំហំ ១៩,២៤ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៨គ្រួសារ លើផ្ទៃដីទំហំ ១៧,៨១ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងរស់នៅជាក់ស្តែង និងដីទំហំ ១,៤៣ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិជើងភ្នំ ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ




កំពង់ស្ពឺ,ថ្ងៃទី...២៩...ខែ...មីនា...ឆ្នាំ២០១៧
ប្រធានក្រុមវាស់វែង

សំ_ណាង

លេខ...២៣៧...ដនសស.កស្ព
បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពង់ស្ពឺ,ថ្ងៃទី...២៩...ខែ...មីនា...ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី ខេត្តកំពង់ស្ពឺ

គាប់ ម៉ាឡៃ

លេខ២៩០/១៧.សសរ
បានឃើញ និងឯកភាព
កំពង់ស្ពឺ,ថ្ងៃទី...២៩...ខែ...មីនា...ឆ្នាំ២០១៧
អភិបាលនៃគណៈអភិបាលខេត្ត និងជា
ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

វ៉ី សំណាង

ឧបសម្ព័ន្ធ....... ចំណុចនិយាមការព្រំដី ដែលស្នើសុំកាត់ចេញពីដែនដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ
ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៨គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង
ស្ថិតនៅភូមិជើងគ្រី ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

តារាងចំណុចនិយាមកា

Projection UTM, Zone 48N, Datum WGS 84

| ID | X | Y | ID | X | Y | 85 | 442759 | 1260414 |
|---|---|---|---|---|---|---|---|---|
| 1 | 442870 | 1260003 | 43 | 443149 | 1260451 | 86 | 442766 | 1260411 |
| 2 | 442871 | 1259980 | 44 | 443139 | 1260452 | 87 | 442765 | 1260405 |
| 3 | 442979 | 1260009 | 45 | 443131 | 1260462 | 88 | 442766 | 1260399 |
| 4 | 442986 | 1259876 | 46 | 443128 | 1260471 | 89 | 442799 | 1260407 |
| 5 | 442987 | 1259780 | 47 | 443128 | 1260493 | 90 | 442803 | 1260387 |
| 6 | 443103 | 1259772 | 48 | 443118 | 1260493 | 91 | 442796 | 1260386 |
| 7 | 443106 | 1259814 | 49 | 443100 | 1260488 | 92 | 442792 | 1260378 |
| 8 | 443112 | 1259878 | 50 | 443051 | 1260481 | 93 | 442805 | 1260360 |
| 9 | 443111 | 1259916 | 51 | 443051 | 1260486 | 94 | 442812 | 1260353 |
| 10 | 443110 | 1259959 | 52 | 443035 | 1260488 | 95 | 442822 | 1260349 |
| 11 | 443108 | 1259976 | 53 | 443035 | 1260512 | 96 | 442819 | 1260305 |
| 12 | 443102 | 1260004 | 54 | 443002 | 1260510 | 97 | 442829 | 1260303 |
| 13 | 443100 | 1260031 | 55 | 443002 | 1260516 | 98 | 442840 | 1260302 |
| 14 | 443123 | 1260065 | 56 | 443005 | 1260551 | 99 | 442840 | 1260282 |
| 15 | 443120 | 1260081 | 57 | 443004 | 1260578 | 100 | 442826 | 1260266 |
| 16 | 443119 | 1260101 | 58 | 442974 | 1260576 | 101 | 442820 | 1260253 |
| 17 | 443118 | 1260107 | 59 | 442971 | 1260576 | 102 | 442811 | 1260245 |
| 18 | 443115 | 1260123 | 60 | 442965 | 1260550 | 103 | 442802 | 1260235 |
| 19 | 443115 | 1260126 | 61 | 442907 | 1260557 | 104 | 442797 | 1260220 |
| 20 | 443133 | 1260128 | 62 | 442905 | 1260570 | 105 | 442806 | 1260219 |
| 21 | 443202 | 1260129 | 63 | 442871 | 1260577 | 106 | 442812 | 1260217 |
| 22 | 443202 | 1260149 | 64 | 442839 | 1260587 | 107 | 442826 | 1260220 |
| 23 | 443166 | 1260150 | 65 | 442830 | 1260588 | 108 | 442831 | 1260224 |
| 24 | 443165 | 1260168 | 66 | 442824 | 1260567 | 109 | 442835 | 1260236 |
| 25 | 443173 | 1260169 | 67 | 442818 | 1260555 | 110 | 442839 | 1260245 |
| 26 | 443170 | 1260200 | 68 | 442802 | 1260553 | 111 | 442843 | 1260253 |
| 27 | 443138 | 1260201 | 69 | 442800 | 1260538 | 112 | 442853 | 1260248 |
| 28 | 443136 | 1260213 | 70 | 442791 | 1260515 | 113 | 442855 | 1260239 |
| 29 | 443128 | 1260214 | 71 | 442789 | 1260496 | 114 | 442848 | 1260203 |
| 30 | 443110 | 1260214 | 72 | 442794 | 1260487 | 115 | 442851 | 1260200 |
| 31 | 443100 | 1260215 | 73 | 442794 | 1260483 | 116 | 442863 | 1260198 |
| 32 | 443095 | 1260220 | 74 | 442803 | 1260480 | 117 | 442855 | 1260165 |
| 33 | 443090 | 1260221 | 75 | 442805 | 1260462 | 118 | 442857 | 1260161 |
| 34 | 443090 | 1260270 | 76 | 442794 | 1260459 | 119 | 442876 | 1260156 |
| 35 | 443092 | 1260276 | 77 | 442790 | 1260478 | 120 | 442867 | 1260126 |
| 36 | 443096 | 1260290 | 78 | 442765 | 1260471 | 121 | 442845 | 1260127 |
| 37 | 443100 | 1260301 | 79 | 442759 | 1260467 | 122 | 442839 | 1260109 |
| 38 | 443101 | 1260306 | 80 | 442753 | 1260467 | 123 | 442839 | 1260097 |
| 39 | 443112 | 1260338 | 81 | 442739 | 1260470 | 124 | 442843 | 1260092 |
| 40 | 443124 | 1260374 | 82 | 442737 | 1260456 | 125 | 442842 | 1260084 |
| 41 | 443127 | 1260383 | 83 | 442710 | 1260411 | 126 | 442857 | 1260086 |
| 42 | 443138 | 1260418 | 84 | 442747 | 1260415 | 127 | 442859 | 1260037 |

កំពង់ស្ពឺ,ថ្ងៃទី..២៨... ខែ..[illegible].... ឆ្នាំ២០១៧
ប្រធានក្រុមវាស់វែង

សំ_ណាង

លេខ...២៣៧....ដនសស.កស្ត
បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពង់ស្ពឺ,ថ្ងៃទី..[illegible]... ខែ..[illegible]... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី ខេត្តកំពង់ស្ពឺ

គាប់ ម៉ាឡៃ

លេខ..២៥០/១៧...
បានឃើញ និងឯកភាព
កំពង់ស្ពឺ,ថ្ងៃទី..២៩... ខែ..[illegible]... ឆ្នាំ២០១៧
អភិបាល នៃគណៈអភិបាលខេត្ត និងជា
ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

ឌុំ សំណាង